# របាយការណ៍ប្រចាំខែ មីនា ឆ្នាំ ២០១៧ របស់នាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ

## ១. ស្ថានភាពមន្ត្រីរាជការរបស់នាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ

នាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទមានមន្ត្រីរាជការសរុបចំនួន ៣៤ នាក់ (ស្រី ១១ នាក់) ក្នុងនោះ មានប្រធាននាយកដ្ឋាន ០១ នាក់ អនុប្រធាននាយកដ្ឋាន ០៤ នាក់ ប្រធានការិយាល័យ ០៤ នាក់ អនុប្រធានការិយាល័យ ១១ នាក់ និងមន្ត្រីក្រោមឱវាទ ១៤ នាក់ (០២ នាក់ ជាមន្ត្រីកម្មសិក្សា)។ ក្នុងចំនួនមន្ត្រីរាជការ ៣៤ នាក់ ក្នុងនោះ មានមន្ត្រីចំនួន ០២ នាក់ បានទៅបំពេញការងារពេញម៉ោងនៅក្នុងគម្រោង និង ០២ នាក់ទៅបន្តការសិក្សា។

## ២. សកម្មភាព និងលទ្ធផលការងារអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ

### ២.១. ការងារឥណទានជនបទ

#### ២.១.១. ការងារឥណទានជនបទគាំទ្រដោយវិទ្យាស្ថានសេដ្ឋកិច្ចជនបទកូរ៉េ

- គិតត្រឹមថ្ងៃទី ២៣ ខែមីនា ឆ្នាំ ២០១៧ គម្រោងឥណទានខ្នាតតូចដែលគាំទ្រថវិកាដោយកូរ៉េ បានផ្តល់ឥណទានសរុបចំនួន **៤៦៨ ៧៧៤ ៨០០,០០ រៀល** (បួនរយហុកសិបប្រាំបីលានប្រាំពីររយចិតសិបបួនពាន់ប្រាំបីរយរៀល) ស្មើនឹង **១១៧ ១៩៣ ,៧០ ដុល្លារអាមេរិក** (មួយរយដប់ប្រាំពីរពាន់មួយរយកៅសិបបីដុល្លារនិងចិតសិបសេន)និងមានអ្នកខ្ចីសរុបចំនួន **១៣៦** នាក់ ក្នុងនោះខេត្តត្បូងឃ្មុំមានផលប័ត្រឥណទានចំនួន **៣៣៥ ៩៩២ ៥០០,០០ រៀល** (បីរយសាមសិបប្រាំលានប្រាំបួនរយកៅសិបពីរពាន់ប្រាំរយរៀល) សម្រាប់អតិថិជន **៨២** នាក់ និងខេត្តកំពង់ចាមមានផលប័ត្រឥណទានចំនួន **១៣២ ៧៨២ ៣០០,០០ រៀល** (មួយរយសាមសិបពីរលានប្រាំពីររយប៉ែតសិបពីរពាន់បីរយរៀល) សម្រាប់អតិថិជន **៥៤** នាក់។
- តំបន់ប្រតិបត្តិការរបស់គម្រោងមានចំនួន **១៨** ភូមិ រួមមាន÷
    - ខេត្តត្បូងឃ្មុំ÷ ភូមិ២ ភូមិ៣ ភូមិ៥ ក្នុងឃុំរកាខ្នុរ ស្រុកក្រូចឆ្មារ ភូមិត្របុស្ស ភូមិខ្លោង ភូមិត្រពាំងដុំ ភូមិអង្គរជ័យ ក្នុងឃុំស្រឡប់ ភូមិវិហារសំបួរ ឃុំរការពរប្រាំ ភូមិស្មោង ឃុំល្មៀង ស្រុកត្បូងឃ្មុំ ភូមិទួលសំបួរ ភូមិថ្មីសំណាង ភូមិទួលមានជ័យ ភូមិអ្នកតាទ្វារ ឃុំព្រះធាតុ ស្រុកអូរាំងឪ ភូមិព្រះអណ្តូង ឃុំកណ្តោលជ្រុំ ស្រុកពញាក្រែក។
    - ខេត្តកំពង់ចាម÷ ភូមិតុងរ៉ុង ភូមិប្រសាទ ភូមិផ្ទះខ្ពស់ ភូមិដូង ក្នុងឃុំតុងរ៉ុង ស្រុកព្រៃឈរ។
- ដើមទុនបង្វិលទទួលពី KREI ដំបូងពេលចាប់ផ្តើមគម្រោង **៣៤៦ ០១៨ ៧៣០ រៀល** (បីរយសែសិបប្រាំមួយលានដប់ប្រាំបីពាន់ប្រាំពីររយសាមសិបរៀល) ស្មើនឹង **៨៦ ៥០៤,៦៨ ដុល្លារ អាមេរិក** (ប៉ែតសិបប្រាំមួយពាន់ប្រាំរយបួនដុល្លារនិងហុកសិបប្រាំបីសេន)។
- ដើមទុនសរុបនៃគម្រោងឥណទាន (Total Asset) គិតត្រឹមថ្ងៃទី ២៣ ខែមីនា ឆ្នាំ ២០១៧ មានចំនួន **៥០៥ ០៥២ ៧៤២,០០ រៀល** (ប្រាំរយប្រាំលានហាសិបពីរពាន់ប្រាំពីររយសែសិបពីររៀល) ស្មើនឹង **១២៦ ២៦៣,១៩ ដុល្លារអាមេរិក** (មួយរយម្ភៃប្រាំមួយពាន់ពីររយហុកសិបបីដុល្លារនិងដប់ប្រាំបួនសេន) (អត្រាប្តូរប្រាក់ ៤០០០៛ ក្នុង ១ USD) កើនលើសដើមទុនដំបូងចំនួន **១៥៩ ០៣៤ ០១២,០០ រៀល** (មួយរយហាសិបប្រាំបួនលានសាមសិបបួនពាន់ដប់ពីររៀល) ស្មើនឹង **៣៩ ៧៥៨,៥០ ដុល្លារអាមេរិក** (សាមសិបប្រាំបួនពាន់ប្រាំពីររយហាសិបប្រាំបីដុល្លារនិងហាសិបសេន)។

▪ **តារាងតុល្យការខេត្តកំពង់ចាម**

ក. ទ្រព្យសកម្ម (Assets)

- ចំនួនប្រាក់នៅក្នុងបេឡា............................................... : ៥ ១៨២ ២០០ រៀល
- ចំនួនប្រាក់ផ្ញើនៅធនាគារ ............................................. : ៤ ០៥៦ ២៣០ រៀល
- ចំនួនប្រាក់ឥណទានកំពុងស្ថិតនៅក្នុងដៃអតិថិជន ................ : ១៣២ ៧៨២ ៣០០ រៀល
- តម្លៃនៅសល់នៃអចលនទ្រព្យ(ដករំលស់បង្គររួច).................. : ៥ ៩៥០ ៦១០ រៀល

**សរុបទ្រព្យសកម្ម...................................................... : ១៤៧ ៩៧១ ៣៤០ រៀល**

ខ. ទ្រព្យមូលធន (Liabilities and Capital)

- ដើមទុនទទួលបានពីប្រទេសកូរ៉េ (ឆ្នាំ២០១៧)...................... : ១៩៧ ៨២២ ១៧០ រៀល
- ចំណូលបង្គរ.......................................................... : (៤៨ ៤៧៥ ១២០) រៀល
- ចំណេញពិតក្នុងខែ..................................................... : (១ ៣៧៥ ៧១០) រៀល

**សរុបទ្រព្យមូលធន .................................................... : ១៤៧ ៩៧១ ៣៤០ រៀល**

▪ **តារាងតុល្យការខេត្តត្បូងឃ្មុំ**

ក. ទ្រព្យសកម្ម (Assets)

- ចំនួនប្រាក់នៅក្នុងបេឡា............................................... : ១៩ ៣៩៩ ៥១២ រៀល
- ចំនួនប្រាក់ផ្ញើនៅធនាគារ ............................................. : ៣ ៣០៣ ៦០០ រៀល
- ចំនួនប្រាក់ឥណទានកំពុងស្ថិតនៅក្នុងដៃអតិថិជន ................ : ៣៣៥ ៩៩២ ៥០០ រៀល
- ចំនួនប្រាក់បម្រុងនឹងបាត់បង់......................................... : (១ ៦១៤ ២១០) រៀល
- **សរុបទ្រព្យសកម្ម...................................................... : ៣៥៧ ០៨១ ៤០២,០០ រៀល**

ខ. ទ្រព្យមូលធន (Liabilities and Capital)

- ដើមទុន (បានទទួលពីកំពង់ចាមទាំងពីរលើករួមអចលនៈទ្រព្យ) : ៣៧៥ ១៩៦ ៥៦៦,០០ រៀល
- ប្រាក់ខាតបង់ (បង្គរ) .................................................. : (២១ ៣៦៤ ៧៨១,៥២) រៀល
- ប្រាក់រកបាន (បង្គរ) .................................................. : ៣ ២៤៩ ៦១៧,៥២ រៀល

**សរុបទ្រព្យមូលធន .................................................... : ៣៥៧ ០៨១ ៤០២,០០ រៀល**

### ២.១.២. លទ្ធផលការងារឥណទានជនបទនៅតាមបណ្តារាជធានី ខេត្ត

គិតត្រឹមថ្ងៃទី ២៣ ខែមីនា ឆ្នាំ ២០១៧ ប្រតិបត្តិការឥណទានជនបទដែលមន្ទីរអភិវឌ្ឍន៍ជនបទខេត្តអនុវត្តផ្ទាល់ និងសហការជាមួយដៃគូ និងសកម្មភាពការងារឥណទានដែលអនុវត្តដោយសហគមន៍សន្សំប្រាក់ បានផ្តល់ឥណទានសរុបចំនួន **៥ ១១៧ ៣២៣ ១០០ រៀល** (ប្រាំពាន់មួយរយដប់ប្រាំពីរលានបីរយម្ភៃបីពាន់មួយរយរៀល) ស្មើនឹង **១ ២៧៩ ៣៣០,៧៨ ដុល្លារអាមេរិក** (មួយលានពីររយចិតសិបប្រាំបួនពាន់បីរយសាមសិបដុល្លារនិងចិតសិបប្រាំបីសេន) (១USD=៤០០០រៀល) មានអ្នកខ្ចីសរុបចំនួន **៦ ១៤១** នាក់នៅភូមិគោលដៅចំនួន **២២០** ភូមិ **៧៩** ឃុំ **៣៤** ស្រុកក្នុងខេត្តគោលដៅចំនួន **១៥** ដូចខាងក្រោម÷

| ល.រ | ខេត្ត | ឥណទានកំពុងប្រើប្រាស់ | ចំនួនអ្នកខ្ចី | ស្ត្រី | ចំនួន | ចំនួន | ចំនួន |
|---|---|---|---|---|---|---|---|

| | | ដោយអតិថិជន ($) | (នាក់) | (នាក់) | ភូមិ | ឃុំ | ស្រុក |
|---|---|---|---|---|---|---|---|
| **I. ប្រតិបត្តិការឥណទានក្រសួងអភិវឌ្ឍន៍ជនបទ** | | | | | | | |
| ១ | កំពង់ចាម | ៣៥៧,០០០.០០ | ១ ១៤២ | ៩៩៨ | ៤៤ | ១៤ | ៥ |
| ២ | ត្បូងឃ្មុំ | ១៩៨,៩៩៨.៤៥ | ២១០ | ១៦៣ | ២៣ | ៧ | ៤ |
| ៣ | បាត់ដំបង | ៤៦,១៤៤.១៨ | ២២៨ | ១៩១ | ១១ | ៧ | ៤ |
| ៤ | ព្រះសីហនុ | ២,២៧៥.០០ | ២៦ | ២២ | ១ | ១ | ១ |
| ៥ | តាកែវ | ៣៩,៤០២.៦៥ | ១៩៣ | ១៤៨ | ១៤ | ៧ | ២ |
| ៦ | កំពង់ស្ពឺ | ៣,២៩៦.០០ | ២៥ | ២៣ | ១ | ១ | ១ |
| ៧ | កំពង់ធំ | ៣,៥៩៧.៥០ | ២៧ | ២៣ | ២ | ១ | ១ |
| ៨ | ស្ទឹងត្រែង | ១,៩៧៥.០០ | ១៧ | ១១ | ១ | ១ | ១ |
| ៩ | កំពង់ឆ្នាំង | ៥,០៣៧.៥០ | ៤១ | ៣៤ | ២ | ១ | ១ |
| សរុប (I) | | ៦៥៧,២២៦.២៨ | ១ ៩០៩ | ១ ៦១៣ | ៩៩ | ៤០ | ២០ |
| **II. ការងារឥណទានសហប្រតិបត្តិការជាមួយអង្គការដៃគូ** | | | | | | | |
| ១ | កំពត | ៨៥,០២៥.០០ | ៣១២ | ៣០៦ | ១៤ | ៨ | ១ |
| ២ | ពោធិ៍សាត់ | ២៥២,០៨២.៥០ | ១ ០៩១ | ១ ០៣៦ | ៣៨ | ១៣ | ៥ |
| ៣ | សៀមរាប | ៣៨,០៧២.៥០ | ១៧១ | ១៥២ | ៧ | ៦ | ៣ |
| ៤ | កោះកុង | ១០,៨១០.០០ | ៥១៥ | ៤៩១ | ១១ | ៥ | ២ |
| ៥ | បន្ទាយមានជ័យ | ៨៤,៩៣៧.៥០ | ៣៦៤ | ២៨៨ | ៤ | ១ | ១ |
| សរុប (II) | | ៤៧០,៩២៧.៥០ | ២ ៤៥៣ | ២ ២៧៣ | ៧៤ | ៣៣ | ១២ |
| **III. ការងារឥណទានសហគមន៍** | | | | | | | |
| ១ | ស្វាយរៀង | ១២៦,៨៧៧.០០ | ១ ២៦៦ | ៧៧០ | ៤៥ | ៥ | ១ |
| ២ | កំពង់ចាម (ស្រុកបាធាយ) | ២៤,៣០០.០០ | ៥១៣ | ៥១៣ | ២ | ១ | ១ |
| សរុប (III) | | ១៥១,១៧៧.០០ | ១ ៧៧៩ | ១ ២៨៣ | ៤៧ | ៦ | ២ |
| **សរុបរួម (I,II,III)** | | **១,២៧៩,៣៣០.៧៨** | **៦ ១៤១** | **៥ ១៦៩** | **២២០** | **៧៩** | **៣៤** |

**២.២. ការងារធនាគារស្រូវ**

មន្ទីរអភិវឌ្ឍន៍ជនបទខេត្តស្វាយរៀង បានធ្វើការបូកសរុប និងសម្របសម្រួលគាំទ្រផ្នែកបច្ចេកទេសគ្រប់គ្រងធនាគារស្រូវដល់សហគមន៍ដែលមានស្រូវសរុបចំនួន **១៥ ៦០០ គ.ក្រ** គិតជាទឹកប្រាក់ស្មើនឹង **២ ៧៣០** ដុល្លារអាមេរិក (ពីរពាន់ប្រាំពីររយសាមសិបដុល្លារអាមេរិក) **ស្ថិតនៅក្នុងជង្រុក។**

## ៣. សកម្មភាពប្រជុំសិក្ខាសាលានិងការងារផ្សេងៗ

- បានចូលរួមកិច្ចប្រជុំលើកទី១ របស់គណៈកម្មាធិការសម្របសម្រួល និងរៀបចំវេទិកាចិន-អាស៊ានលើកទី១១ ស្តីពីការអភិវឌ្ឍសង្គម និងកាត់បន្ថយភាពក្រីក្រ កាលពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៧ នៅសាលប្រជុំជាន់ទី ១ ទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ
- បានចូលរួមក្នុងពិធីអបអរសាទរទិវាអន្តរជាតិនារី ៨មីនា ឆ្នាំ២០១៧ ខួបលើកទី១០៦ ក្រោមអធិបតីភាព ឯកឧត្តមបណ្ឌិត **អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ កាលពីថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៧ នៅភោជនីយដ្ឋានទន្លេបាសាក់២
- បានចូលរួមក្នុងកិច្ចប្រជុំពិភាក្សាអំពីដំណើរការរៀបចំសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៦ និងលើកទិសដៅការងារ ឆ្នាំ២០១៧ របស់ក្រសួងអភិវឌ្ឍន៍ជនបទកាលពីថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៧នៅសាលប្រជុំជាន់ទី ៣ ទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ
- បានចូលរួមកិច្ចប្រជុំពិនិត្យឡើងវិញការអនុវត្តថវិកាកម្មវិធីឆ្នាំ២០១៦ និងទិសដៅឆ្នាំ២០១៧ ក្រោម អធិបតីភាព ឯកឧត្តម **ហួត សារីម** អនុរដ្ឋលេខាធិការ ក្រសួងអភិវឌ្ឍន៍ជនបទ កាលពីថ្ងៃទី ០៧ ខែមីនា ឆ្នាំ ២០១៧ នៅសាលប្រជុំជាន់ទី ១ ទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ
- បានចូលរួមក្នុងកិច្ចប្រជុំពិភាក្សា និងពិនិត្យការរៀបចំសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ ២០១៦ និងលើកទិសដៅការងារ ឆ្នាំ២០១៧ របស់ក្រសួងអភិវឌ្ឍន៍ជនបទ ក្រោមអធិបតីភាព ឯកឧត្តម **សួស គង់** រដ្ឋលេខាធិការ និងជាប្រធានគណៈកម្មាធិការរៀបចំសន្និបាត កាលពីថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៧ នៅសាលប្រជុំជាន់ទី ៣ ទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ
- បានចូលរួមក្នុងកម្មវិធីកាត់ឬសសីមា និងសម្ពោធសមិទ្ធផលនានាក្នុងវត្តតុណ្ឌបព្វតារាម (ហៅវត្តភ្នំចំពុះ) ក្រោមអធិបតីភាព ឯកឧត្តមបណ្ឌិត **អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ តំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** កាលពីថ្ងៃទី ១៩ ខែមីនា ឆ្នាំ ២០១៧ នៅខេត្តកំពង់ឆ្នាំង
- បានចូលរួមក្នុងកិច្ចប្រជុំពិភាក្សា និងពិនិត្យការរៀបចំសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ ២០១៦ និងលើកទិសដៅការងារ ឆ្នាំ២០១៧ របស់ក្រសួងអភិវឌ្ឍន៍ជនបទ ក្រោមអធិបតីភាព ឯកឧត្តម **សួស គង់** រដ្ឋលេខាធិការ និងជាប្រធានគណៈកម្មាធិការរៀបចំសន្និបាត កាលពីថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៧ នៅសាលប្រជុំជាន់ទី ៣ ទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ
- បានចូលរួមក្នុងកិច្ចប្រជុំស្តីពីដំណើរការរៀបចំការប្រឡងជ្រើសរើសមន្ត្រីក្របខណ្ឌឆ្នាំ២០១៧ កាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៧ នៅសាលប្រជុំជាន់ទី ៣ ទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ

**៤.ទិសដៅអនុវត្តបន្ត**

- បន្តពង្រីកគម្រោងឥណទានទៅតាមបណ្តាខេត្តផ្សេងៗ
- បន្តរៀបចំចងក្រងឯកសារគោលការណ៍ និងនីតិវិធីសម្រាប់គ្រប់គ្រងដំណើរការសហគមន៍សន្សំប្រាក់
- បន្តចុះពិនិត្យ និងវាយតម្លៃគម្រោងឥណទានជនបទតាមបណ្តារាជធានីខេត្តតាមផែនការគ្រោងទុក
- ជំរុញការផ្តល់ឥណទាន និងប្រមូលត្រឡប់មកវិញឲ្យបានក្នុងកម្រិតអតិបរមាសម្រាប់ខេត្តគោលដៅដែលគ្រប់គ្រងផ្ទាល់ និងបង្កើនកិច្ចសហការជាមួយអង្គការដៃគូ
- បន្តជំរុញ និងលើកទឹកចិត្តប្រជាពលរដ្ឋឲ្យបង្កើតសហគ្រាសខ្នាតគ្រួសារនិងខ្នាតតូច
- ពង្រឹងប្រព័ន្ធប្រតិបត្តិការក្នុងការផ្តល់សេវាជូនប្រជាពលរដ្ឋដូចជាការងារឥណទានសាច់ប្រាក់ និងមិនមែនសាច់ប្រាក់ការបណ្តុះបណ្តាលបំនិនជីវិត ការរកទីផ្សារសម្រាប់ផលិតផលជនបទជាដើម
- បន្តរៀបចំឯកសារគោលការណ៍នីតិវិធីនិងឯកសារគតិយុត្តិតាមវិស័យដូចជា ឥណទានជនបទសហគ្រាសខ្នាតតូចនិងរកទីផ្សារសម្រាប់ផលិតផលជនបទ
- បន្តបង្កើនកិច្ចសហប្រតិបត្តិការផ្នែកបច្ចេកទេសជាមួយវិស័យឯកជននិងដៃគូអភិវឌ្ឍន៍នានា
- បន្តពង្រឹងសមត្ថភាពមន្ត្រីរាជការតាមរយៈការបើកវគ្គនៅនឹងកន្លែង ការបញ្ជូនមន្ត្រីឲ្យទៅចូលរួមសិក្ខាសាលាវគ្គបណ្តុះបណ្តាលនានា ការផ្លាស់ប្តូរបទពិសោធន៍រវាងមន្ត្រីនាយកដ្ឋានជាមួយនឹងមន្ត្រីការិយាល័យអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទនៃមន្ទីរអភិវឌ្ឍន៍ជនបទរាជធានីខេត្ត និងស្ថាប័នផ្សេងៗ និងលើកទឹកចិត្តឲ្យមន្ត្រីសិក្សាស្រាវជ្រាវពីចំណេះដឹងថ្មីៗបន្ថែមដោយខ្លួនឯង
- ពង្រឹងការតាមដាន និងវាយតម្លៃដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តការងារ ។